ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ
លេខ ១១៤១២ អពដ

# សារលិខិតអបអរសាទរ

## សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ក្នុងឱកាស "តំបន់ប្រាសាទសំបូរព្រៃគុក" ត្រូវបានចុះក្នុងបញ្ជីបេតិកភណ្ឌពិភពលោក

ក្នុងឱកាសប្រកបដោយមោទនភាពជាតិ សម្រាប់ប្រទេសនិងប្រជាជនកម្ពុជាទាំងមូល តាងនាមថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃអគ្គនាយកដ្ឋានពន្ធដារ និងក្នុងនាមខ្ញុំបាទផ្ទាល់ សូមគោរពអនុញ្ញាតសម្តែងនូវអំណរសាទរយ៉ាងស្មោះអស់ពីដួងចិត្តជូនចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ក្នុងឱកាសដែល **"តំបន់ប្រាសាទសំបូរព្រៃគុក ត្រូវបានគណៈកម្មការបេតិកភណ្ឌពិភពលោក សម្រេចចុះក្នុងបញ្ជីបេតិកភណ្ឌពិភពលោក"** កាលពីថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១៧ ក្នុងកិច្ចប្រជុំលើកទី៤១ នៅទីក្រុង Krakow ប្រទេសប៉ូឡូញ។

នេះគឺជាសមិទ្ធផលដ៏សំខាន់មួយទៀតរបស់រាជរដ្ឋាភិបាលសម្រាប់ជាចំណងដៃជូនប្រជាជនកម្ពុជា។ ប្រជាជាតិកម្ពុជាទាំងមូលពិតជាមានមោទនភាពយ៉ាងក្រៃលែង រស់នៅប្រកបដោយកិត្តិយស និងសេចក្តីថ្លៃថ្នូ ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់ ប្រកបដោយបញ្ញាញាណគតិបណ្ឌិតរបស់**សម្តេចតេជោ នាយករដ្ឋមន្ត្រី** ដែលសម្តេចតែងតែលះបង់ បូជាកម្លាំងកាយ ចិត្ត ប្រាជ្ញា ស្មារតី ដោយមិនគិតពីការនឿយហត់ ដោយមិនត្រឹមតែរក្សាបាននូវសុខសន្តិភាព ស្ថិរភាពនយោបាយប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងយកចិត្តទុកដាក់លើកកម្ពស់កិត្តិយសប្រជាជាតិខ្មែរនៅលើឆាកអន្តរជាតិថែមទៀតផង។

ឆ្លៀតឱកាសប្រកបដោយមោទនភាពជាតិដ៏ក្រៃលែងនេះ ខ្ញុំបាទសូមលើកហត្ថបួងសួងដល់វត្ថុស័ក្តិសិទ្ធិក្នុងលោក ទេវតាថែរក្សាទឹកដីនៃព្រះរាជាណាចក្រកម្ពុជា គុណបុណ្យព្រះរតនត្រ័យកែវទាំងបី ទេវតាថែរក្សាឆ្នាំថ្មី សូមព្រះអង្គតាមជួយអភិបាល ប្រោសព្រំសព្វសាធុការពរជ័យគ្រប់ប្រការ ចំពោះ**សម្តេចតេជោ នាយករដ្ឋមន្ត្រី** សូម **សម្តេច** សមប្រកបនឹងសុខភាពល្អបរិបូណ៌ ពលានុភាពមាំមួន ប្រាជ្ញាញាណភ្លឺថ្លា ជន្មាយុយឺនយូរ និងសូមទទួលបាននូវជោគជ័យថ្មីៗធំធេងថែមទៀត ក្នុងការបន្តដឹកនាំមាតុភូមិកម្ពុជាឆ្ពោះទៅរកសុខសន្តិភាព ស្ថិរភាព វិបុលភាព និងអភិវឌ្ឍនភាពលើគ្រប់វិស័យ។

ជាថ្មីម្តងទៀត ខ្ញុំបាទថ្នាក់ដឹកនាំនិងមន្ត្រីរាជការពន្ធដារ សូមប្តេជ្ញាចិត្តខ្ពស់ក្នុងការអនុវត្តប្រកបដោយជោគជ័យនូវគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាលនីតិកាលទីប្រាំនៃរដ្ឋសភា និងសូមបួងសួងដល់ទេវតាឆ្នាំថ្មី សូមប្រសិទ្ធពរបវរមហាប្រសើរ ជូនចំពោះ**សម្តេចតេជោ នាយករដ្ឋមន្ត្រី** និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** ព្រមទាំងបុត្រា បុត្រី ចៅប្រុស ចៅស្រី ជាទីស្រឡាញ់ សូមសមប្រកបដោយពុទ្ធពរទាំងបួនប្រការ គឺអាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា មេត្តាទទួលនូវអភិវន្ទនកិច្ចដ៏ខ្ពង់ខ្ពស់ និងភក្តីភាពដ៏ស្មោះស្ម័គ្របំផុត អំពីខ្ញុំបាទ។

គោរពជូនពរ និងអបអរសាទរ នៅរាជធានីភ្នំពេញ, ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៧

**ប្រតិភូរាជរដ្ឋាភិបាល**
**ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ**

**គង់ វិបុល**